**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..១៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- គ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកចាប់ពីចំណុចបង្កើតរហូតដល់ការបោះបោលចុងក្រោយ
- ទប់ស្កាត់ការនាំចូលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដើម្បីបោះចោល
- កាត់បន្ថយការនាំចូលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួចដែលនៅមានគុណភាពប្រើប្រាស់បាន
- ទប់ស្កាត់ការសាយភាយសារជាតុគ្រោះថ្នាក់ពីសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកចូលក្នុងបរិស្ថានទឹក ដី និងខ្យល់។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**បរិក្ខារអគ្គិសនី** សំដៅដល់គ្រឿងប្រដាប់ប្រើប្រាស់ដែលដើរដោយចរន្តអគ្គិសនី។

**បរិក្ខារអេឡិចត្រូនិក** សំដៅដល់គ្រឿងម៉ាស៊ីនឬគ្រឿងប្រដាប់ប្រើប្រាស់ដែលដើរដោយចរន្តអគ្គិសនីបង្កើតជាចរន្តអេឡិចត្រុងនៅលើបន្ទះសៀគ្វី។

**សំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក** សំដៅដល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលលែងត្រូវការប្រើតែនៅរូបរាងទាំងមូល និងបំណែកឬកម្ទេចកម្ទីដែលសេសសល់ពីការដោះបំបែក ឬការកែច្នៃនៃបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទាំងឡាយ។

**បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួច** សំដៅដល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលធ្លាប់បានប្រើរួចហើយ ប៉ុន្តែអាចនៅប្រើបន្តទៀតបាន។

**ការកែច្នៃឡើងវិញ** សំដៅដល់ដំណើរការទាញយកធនធានពីសំណល់ ទៅបំប្លែងជាធនធានសម្រាប់ផលិតឡើងវិញ។

**ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់ដំណើរការដកយក ឬកម្ទេចចោលជាតិពុល ឬក៏សារជាតុគ្រោះថ្នាក់នានាដែលមានផ្ទុកក្នុងសំណល់ ក្នុងគោលដៅសុវត្ថិភាពបរិស្ថាននៅពេលបោះបង់ចោល។/.

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងបរិស្ថានជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

ក្រសួងបរិស្ថាន ត្រូវបែងចែកការងារគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅមន្ទីរបរិស្ថានរាជធានី ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្តល់សិទ្ធិគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅមន្ទីរបរិស្ថានរាជធានី ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ក្រសួងឧស្សាហកម្មនិងសិប្បកម្មមានភារកិច្ចគ្រប់គ្រងមូលដ្ឋានផលិតកម្មនៃការកែច្នៃឡើងវិញវត្ថុធាតុដើមពីសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក បន្ទាប់ពីមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមហើយ។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកតាមការស្នើសុំរបស់ក្រសួងបរិស្ថាន។

## ជំពូកទី៣
## ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

### ផ្នែកទី១
### វិធានការគ្រប់គ្រង

**មាត្រា៧ .-**

រាល់ការបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬក៏នៅទីសាធារណៈនានា និងការដុត ឬការវាយបំបែកសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលបង្កឱ្យគ្រោះថ្នាក់ដល់បរិស្ថានឬសុខភាពសាធារណៈ ត្រូវហាមឃាត់។

**មាត្រា៨ .-**

គោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៩ .-**

ក្រសួងបរិស្ថានត្រូវធ្វើបញ្ជីសារពើភណ្ឌអំពីប្រភព ប្រភេទ ទីតាំង និងបរិមាណសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

**មាត្រា១០.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តកម្ម ឬទុ្យ ផុតសំណល់ និងការបង្កើតទីលានបោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំ និងបំពេញទម្រង់បែបបទ នៅក្រសួងបរិស្ថាន ឬនៅមន្ទីរបរិស្ថានរាជធានី ខេត្ត យោងទៅតាមកម្រិតនៃការទទួលខុសត្រូវដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ទម្រង់បែបបទនិងគំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

រាល់ការប្រកបអាជីវកម្មឬវិនិយោគដូចមានចែងក្នុងវាក្យខណ្ឌទី១ខាងលើ ត្រូវតែមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថានឬមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា១១.-**

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តកម្ម ឬទុ្យផុតសំណល់ និងការបង្កើតទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិច-ត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១២.-**

រាល់លិខិតអនុញ្ញាតដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវបង់កម្រៃសេវា។ កម្រៃសេវានៃការសុំលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

ក្រសួងបរិស្ថាននិងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការអប់រំនិងផ្សព្វផ្សាយអំពីផលប៉ះពាល់បណ្តាលមកពីសារធាតុគ្រោះថ្នាក់ផ្ទុកក្នុងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក។

## ផ្នែកទី២
## ភារកិច្ចទូទៅ

**មាត្រា១៤.-**

បុគ្គលដែលមានសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- រក្សាទុកសំណល់នៅទីសុវត្ថិភាពនិងដាក់ដោយឡែកពីសំរាមលំនៅឋាន។

ខ- បញ្ជូនសំណល់ទៅទីតាំងកែច្នៃឬកន្លែងប្រមូលផ្តុំសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក តាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៥.-**

អ្នកជួសជុលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ទុកដាក់សំណល់បំណែកឬកម្ទេចកម្ទីដែលសេសសល់ពីការជួសជុលរបស់ខ្លួនដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីការជួសជុលរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីការជួសជុលរបស់ខ្លួន ត្រូវកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៦.-**

ម្ចាស់ទីតាំងអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ដំឡើង ឬកែច្នៃសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- អនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាននៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

ខ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីអាជីវកម្មរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីអាជីវកម្មរបស់ខ្លួនដែលកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៧.-**

បុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ប្រមូលនិងទុកដាក់សំណល់ចេញពីដំណើរការផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- បំពាក់ឧបករណ៍ត្រួតពិនិត្យការបំពុលបរិស្ថាន។

គ- រៀបចំទិន្នន័យសំណល់ដែលបង្កើតពីផលិតកម្មរបស់ខ្លួន។

ឃ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលបង្កើតពីផលិតកម្មរបស់ខ្លួនដែលកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៨.-**

ក្នុងករណីមានគ្រោះថ្នាក់នៅលើទីតាំងឬអំឡុងពេលដឹកជញ្ជូនសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក បុគ្គលដែលជាអ្នកទទួលខុសត្រូវ ត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុតឬស្ថាប័នជំនាញដើម្បីចាត់វិធានការលុបបំបាត់ការបំពុលបរិស្ថាននោះ។

## ជំពូកទី៤
## ការនាំចូល ការនាំចេញបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួច

**មាត្រា១៩.-**

បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួចមួយចំនួន ត្រូវបានចាត់ទុកជាប្រភេទទំនិញហាមឃាត់។ ការនាំចូល ការនាំចេញនូវទំនិញប្រភេទនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន។

**មាត្រា២០.-**

បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រើប្រាស់រួចមួយចំនួនដូចមានចែងក្នុងមាត្រា១៩ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី៥
## ការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក

**មាត្រា២១.-**

រដ្ឋមន្ត្រីក្រសួងបរិស្ថានមានសិទ្ធិចាត់តាំងមន្ត្រីជំនាញចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា២២.-**

ក្នុងពេលចុះបំពេញការងារ មន្ត្រីជំនាញនៃក្រសួងបរិស្ថានត្រូវស្នើសុំកិច្ចសហការនិងសម្របសម្រួលពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត តាមការចាំបាច់។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា២៣.-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន៖

-ការព្រមានជាលាយលក្ខណ៍អក្សរ

-ការផ្អាកលិខិតអនុញ្ញាតប្រកបអាជីវកម្មជាបណ្តោះអាសន្ន

-ការលុបលិខិតអនុញ្ញាតប្រកបអាជីវកម្មជាស្ថាពរ។

ទណ្ឌកម្មខាងលើនេះ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ចដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យចំពោះអំពើល្មើស ដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់

ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា២៤.-**

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណនៃជនល្មើស ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ឬមន្ត្រីអធិការកិច្ចដែលត្រូវបានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើការត្រួតពិនិត្យលើគ្រប់ទីតាំងទាក់ទងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចរឹបអូសវត្ថុតាងនៃបទល្មើស។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្តឹងចំពោះសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទៅតុលាការរដ្ឋបាលវណីមានសមត្ថកិច្ច។

**មាត្រា២៥.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ឬផ្អាកលិខិតអនុញ្ញាតប្រកបអាជីវកម្មជាបណ្តោះអាសន្ន ឬលុបលិខិតអនុញ្ញាតប្រកបអាជីវកម្មជាស្ថាពរ ចំពោះម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម ឬទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

ក្នុងករណីបង្កព្យសនកម្ម ម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម ឬទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតបរិស្ថាន និងសុខភាពសាធារណៈដែលខ្លួនបានបង្ក ដោយពុំទាន់គិតដល់ការសងការខូចខាតដែលកើតឡើងដល់ជនរងគ្រោះផ្សេងទៀតឡើយ។ ការវាយតម្លៃទំហំខូចខាតបរិស្ថាននិងសុខភាពសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។/៣

**មាត្រា២៦ ._**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៤០ ០០០(បួនម៉ឺន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តល្មើសដូចខាងក្រោម៖

- បញ្ចេញឬបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬក៏នៅតាមទីសាធារណៈនានា ក្រៅពីការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច

- ដុតឬវាយបំបែកសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ដែលបង្កឱ្យគ្រោះថ្នាក់ដល់បរិស្ថាន។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២៧ ._**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា២៦នៃអនុក្រឹត្យនេះ។

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១ ០០០ ០០០(មួយលាន)រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា២៨ ._**

បុគ្គលដែលនាំចូលបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលប្រើប្រាស់រួច ដែលត្រូវបានចាត់ទុកជាប្រភេទទំនិញហាមឃាត់ដាច់ខាតនូវការនាំចូល ត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

**មាត្រា២៩ ._**

បុគ្គលដែលប្រកបអាជីវកម្មដោយគ្មានលិខិតអនុញ្ញាតប្រកបអាជីវកម្ម ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល និងតម្រូវឱ្យផ្អាកសកម្មភាពជាបន្ទាន់។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៣០ ._**

នីតិបុគ្គល អាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដូចមានចែងក្នុងមាត្រា២៩នៃអនុក្រឹត្យនេះ។/

នីតិបុគ្គលត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៥ ០០០ ០០០(ប្រាំលាន)រៀល។

ករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលក្នុងអំឡុងពេល២ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៣១.-**

អំពើក្លែងលិខិតអនុញ្ញាត ឬឯកសារសាធារណៈផ្សេងទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**មាត្រា៣២.-**

មន្ត្រីមានសមត្ថកិច្ច ដោយចេតនាបិទបាំងអំពើល្មើសរបស់ម្ចាស់ទីតាំងផលិតកម្ម ទីតាំងប្រមូលដឹកជញ្ជូន ទីតាំងដោះបំបែក ទីតាំងធ្វើប្រព្រឹត្តកម្ម និងទីលានបោះបង់ចោលសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៣៣.-**

ការវិនិយោគលើការកែច្នៃឡើងវិញគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ដែលបង្កើតក្នុងស្រុក ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៤.-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន បុគ្គលដែលបាននិងកំពុងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក សំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក មានរយៈពេល១២(ដប់ពីរ)ខែ ដើម្បីមកបំពេញទម្រង់បែបបទស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ